# អនុសញ្ញាស្ដីអំពីការបង្ការ និងផ្ដន្ទាទោស
# ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍

# CONVENTION ON PREVENTION
# AND PUNIHMENT OF CRIME OF GENOCIDE

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងការបរទេស

MINISTÈRE

des

AFFAIRES ETRANGERES

n° 412-30/33

ROYAUME DU CAMBODGE

Phnom-Penh, le 19 Août 1950

Le Ministre des Affaires Etrangères

à MONSIEUR LE SECRETAIRE GENERAL DES NATIONS-UNIES

à LAKE SUCCESS (NEW-YORK)

REFERENCE : Ma lettre n°431 -30/33 du 19 Août 1950
Votre lettre CN/113-1950 du 3 Août 1950
CN/118-1950 du 3 Août 1950

Monsieur le Secrétaire Général,

J'ai l'honneur de préciser que le Royaume du Cambodge accepte d'adhérer sans aucune réserve à la convention pour la prévention et la repression du crime de génocide.

Veuillez agréer, Monsieur le Secrétaire Général, l'assurance de ma haute considération./.

SON SANN

---

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងការបរទេស

MINISTERE

des

AFFAIRES ETRANGERES

n° 414-30/33

Phnom-Penh, le 19 Août 1950

Le Ministre des Affaires Etrangères

à MONSIEUR LE SECRETAIRE GENERAL DES NATIONS-UNIES,

à LAKE-SUCCESS (NEW YORK)

OBJET : Adhésion à la Convention pour la prévention et la repression du crime de Génocide.
REFERENCE : Votre lettre n° LEG-318-2-03 du 31 Mai 1950

Monsieur le Secrétaire Général,

J'ai l'honneur de vous faire connaître que le Gouvernement de Sa Majesté le Roi du Cambodge, réuni en Conseil des Ministres, le 18 Août 1950, déclare expressément adhérer à la Convention pour la prévention et la répression du crime de Génocide ouverte à la signature à Paris le 9 Décembre 1948 et à l'adhésion à partir du 1er Janvier 1950.

Je vous demande, Monsieur le Secrétaire Général, de bien vouloir considérer la présente lettre comme l'instrument officiel d'adhésion du Royaume du Cambodge à la dite convention dans les conditions de l'article XI.

Je saisis cette occasion, pour vous exprimer toute la satisfaction du Gouvernement Royal du Cambodge de participer à la convention pour la prévention et la repression du crime de Génocide.

Veuillez agréer, Monsieur le Secrétaire Général, l'assurance de ma haute considération./.

SON SANN

# អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោស ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍

CONVENTION ON PREVENTION AND PUNIHMENT OF CRIME OF GENOCIDE

Approved and proposed for signature and ratification or accession General Assembly Resolution 260A(III) of 9 December 1948.
Entry into force: 12 January 1951. in accordance with article XIII

**គ្រប់ភាគីនៃអនុសញ្ញា**

ដោយពិនិត្យសេចក្តីថ្លែងការណ៍ ដែលធ្វើឡើងដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិនៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៩៦ (I) ចុះថ្ងៃទី ១១ ធ្នូ ១៩៤៦ ដែលចែងថា ការប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋតាមលក្ខណៈច្បាប់អន្តរជាតិ និងដែលផ្ទុយពីគោលដៅរបស់អង្គការសហប្រជាជាតិ ហើយដែលត្រូវផ្តន្ទាទោសដោយពិភពនៃអារ្យប្រទេស ........

ដោយបានទទួលស្គាល់ថា នៅគ្រប់សម័យកាលនៃប្រវត្តិសាស្ត្រការប្រល័យពូជសាសន៍បានបណ្តាលមានការបាត់បង់ និងខូចខាតយ៉ាងធ្ងន់ធ្ងរដល់មនុស្សជាតិ.........

ដោយជឿជាក់ថា ដើម្បីរំដោះមនុស្សជាតិឱ្យរួចផុតពីមហាភ័យដ៏គួរឱ្យខ្ពើមរអើមនេះត្រូវតែឱ្យមានជា ចាំបាច់នូវសហប្រតិបត្តិការអន្តរជាតិនោះ ......

**បានស្របមតិគ្នាលើចំនុចនានាខាងក្រោមនេះ :**

**មាត្រា ១**

គ្រប់ភាគីទាំងអស់បានបញ្ជាក់អះអាងថាការប្រល័យពូជសាសន៍ទោះជាត្រូវធ្វើឡើងនៅពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាមក្តីគឺឧក្រិដ្ឋកម្មតាមលក្ខណៈច្បាប់អន្តរជាតិ ហើយដែលគូភាគីទាំងអស់មានភារកិច្ចត្រូវបង្ការ និងផ្តន្ទាទោស ។

**មាត្រា ២**

នៅក្នុងអនុសញ្ញានេះការប្រល័យពូជសាសន៍មានន័យថា ជាអំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោមនេះ ដែលត្រូវបានធ្វើឡើងក្នុងបំណងបំផ្លាញទោះទាំងស្រុងក្តី ឬក៏ខ្លះៗក្តី ដល់ប្រជាជាតិមួយពូជសាសន៍មួយ ឬក្រុមសាសន៍មួយ ឬក្រុមសាសន៍មួយដូចជា :

ក.- ការសំលាប់សមាជិកទាំងឡាយនៅក្នុងក្រុម

ខ.- បង្កការឈឺចាប់ និងខូចខាតជាដំណាំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។

គ.- បង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកំទេចបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម ។

ឃ.- ដាក់បង្ខំនូវវិធានការណ៍នានាដែលបង្ការមិនឱ្យមានកំណើតទារកនៅក្នុងសង្គម ។

ង.- យកកូនក្មេងចេញពីសង្គមមួយទៅដាក់នៅក្នុងសង្គមមួយទៀតដោយបង្ខិតបង្ខំ ។

## មាត្រា ៣

ការព្រឹត្តនានាខាងក្រោមនេះ នឹងត្រូវផ្ដន្ទាទោស

ក.- ការប្រល័យពូជសាសន៍

ខ.- ការរួមគំនិតដើម្បីធ្វើប្រលយពូជសាសន៍

គ.- ជំរុញដោយផ្ទាល់ និងជាសាធារណៈដើម្បីធ្វើការប្រល័យពូជសាសន៍ ។

ឃ.- ការប៉ុនប៉ងធ្វើការប្រលយពូជសាសន៍

ង.- ការឃុបឃិត ឬចូលដៃក្នុងការប្រល័យពូជសាសន៍

## មាត្រា ៤

បុគ្គលណាដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើណាមួយដែលបានរៀបរាប់ក្នុងមាត្រា ៣ ខាងលើនឹងត្រូវផ្ដន្ទាទោសទោះបីបុគ្គលនោះជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវស្របតាមរដ្ឋធម្មនុញ្ញក្ដី ជាអ្នករដ្ឋការក្ដី ឬជាឯកជនក្ដី ។

## មាត្រា ៥

ភាគីទាំងឡាយមានភារកិច្ចអនុម័យតាមក្របខ័ន្ធនៃរដ្ឋធមនុញ្ញរៀង១ខ្លួននូវច្បាប់ជាចាំបាច់ ដើម្បីធ្វើឱ្យបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមានប្រសិទ្ធិភាព និងជាពិសេសដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពដល់ទណ្ឌកម្មនានាដែលត្រូវធ្វើចំពោះមនុស្សដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើណាមួយទៀតដែលរៀបរាប់ក្នុងមាត្រា ៣ខាងលើ ។

## មាត្រា ៦

បុគ្គលទាំងឡាយណាដែលបានត្រូវជាប់ចោទពីបទប្រល័យពូជសាសន៍ឬអំពើណាមួយទៀតដែលបានរៀបរាប់ក្នុងមាត្រាខាងលើនឹងត្រូវកាត់ទោសដោយតុលាការដែលមានសមតកិច្ចរស់រដ្ឋណាដែលអំពើនោះត្រូវបានធ្វើឡើងនៅលើទឹកដីខ្លួន ឬក៏ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែលនីតិក្រម (ទម្រង់ការរបស់ច្បាប់) របស់ខ្លួនត្រូវបានភាគីទាំងអស់យល់ព្រមទទួលស្គាល់ ។

## មាត្រា ៧

ការប្រល័យពូជសាសន៍ និងអំពើឯទៀតដែលបានរៀបរាប់ក្នុងមាត្រា ៣ ខាងលើមិនត្រូវចាត់ទុកថាជារឿងនយោបាយទេ។ ជនជាប់ចោទពីបទប្រល័យពូជសាសន៍ ទោះជាបានរត់ចេញពីប្រទេសខ្លួនទៅពួនទៅប្រទេសក្រៅណាមួយក៏ដោយ ក៏ពុំមានសិទ្ធិសុំជ្រកកោនដោយមូលហេតុនយោបាយបានឡើយ ព្រោះវាមិនមែនជារឿងនយោបាយ។ ផ្ទុយទៅវិញវាជារឿងប្រល័យពូជសាសន៍ ដែលត្រូវតែនាំជនជំពូកនោះត្រឡប់ទៅស្រុកកំណើតវិញដើម្បីផ្ដន្ទាទោសពីបទប្រល័យពូជសាសន៍។

ភាគីទាំងឡាយសន្យាថា នៅក្នុងករណីនេះនឹងយល់ព្រមឱ្យមានការចាប់ខ្លួនជនដែលបានប្រព្រឹត្តអំបើប្រល័យពូជសាសន៍នេះហើយបញ្ជូនចេញពីប្រទេសខ្លួនឱ្យត្រឡប់ទៅប្រទេសដើមវិញដើម្បីកាត់ទោស។ ការអស់ទាំងនេះត្រូវអនុលោមទៅតាមច្បាប់ ហើយនិងសេចក្ដីព្រមព្រៀងទាំងឡាយជាធរមាន។

## មាត្រា ៨

ភាគីណាមួយក៏ដោយ ក៏អាចសើដល់អង្គការមានសមតកិច្ចទាំងឡាយនៃរដ្ឋធម្មនុញ្ញសហប្រជាជាតិក្នុងរឿងប្រល័យ ពូជសាសន៍នេះ។ ធ្វើតាមវិធីនេះ ជាការសមស្របក្នុងកិច្ចបង្ការ និងកំចាត់អំពើប្រល័យពូជសាសន៍ ឬអំពើណាមួយទៀតដែលបានរៀបរាប់នៅក្នុងមាត្រា ៣ខាងលើ ។

## មាត្រា ៩

បីរដ្ឋជាភាគីមានការវិវាទគ្នាអំពីប្រការផ្សេងៗ ដូចជាការបកស្រាយន័យនៃអនុសញ្ញាការអនុវត្តន៍ការបំពេញជារកិច្ចតាម អនុសញ្ញានេះជាដើម ឬជម្លោះដែលទាក់ទងទៅនឹងការទទួលខុសត្រូវរបស់រដ្ឋក្នុងវិស័យប្រល័យពូជសាសន៍ឬអំពើណាមួយដែលបានចែងក្នុងមាត្រានោះ គូវិវាទណាមួយក៏អាចដាក់ជូនតុលាការអន្តរជាតិនូវពាក្យស្នើសុំឱ្យជួយដោះស្រាយជម្លោះនេះដែរ ។

## មាត្រា ១០

អត្ថបទនៃអនុសញ្ញានេះដែលចែងជាភាសា ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្បាញ៉ុល មានគុនភាពនិងតម្លៃដូចគ្នា ហើយចុះនៅថ្ងៃទី ៩ ១៩៤៨ ។

## មាត្រា ១១

អនុសញ្ញានេះនឹងបើកជំហរសំរាប់ចុះហត្ថលេខា រហូតដល់ថ្ងៃទី៣១ ធ្នូ ១៩៤៩ សំរាប់គ្រប់គ្រងរដ្ឋដែលជាសមាជិកនៃអង្គការសហប្រជាជាតិហើយនិងសំរាប់រដ្ឋដែលមិនមែនជាសមាជិកឯទៀតដែលមហាសន្និបាតបានអញ្ជើញឱ្យចុះហត្ថលេខា ។

អនុសញ្ញានេះត្រូវទទួលឱ្យសច្ចប័ន (ការចូលជាសមាជិកពេញអង្គ) អំពីរដ្ឋដែលជាភាគី ហើយឯកសារនៃការសច្ចាប័ននោះត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

ក្រោយពីថ្ងៃទី១ មករា ១៩៥០ អនុសញ្ញានេះនឹងប្រកប ដោយការទទួលស្គាល់និងចូលរួមពីសំណាក់រដ្ឋនានាដែលសមាជិក នៃអង្គការសហប្រជាជាតិនិងពីសំនាក់រដ្ឋឯទៀតដែលមិនមែនជាសមាជិក ប៉ុន្តែបានទទួលសេចក្តីអញ្ជើញដូចដែលបានលើកពីខាងដើមនៃមារតា ១១នេះមក ។

ឯកសារនៃកិច្ចចូលរួម នឹងត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## មាត្រា ១២

នៅគ្រប់ពេលទាំងអស់ ភាគីទាំងឡាយអាចឱ្យដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការនៃអង្គការសហប្រជា-ជាតិ ពីការពង្រីកកិច្ចអនុវត្តន៍នៃអនុសញ្ញានេះទៅលើតំបន់ទាំងមូល ឬផ្នែកណាមួយដែលភាគីនេះមានភារៈទទួលខុសត្រូវលើការដឹកនាំនៃទំនាក់ទំនងផ្នែកការបរទេសនោះ ។

## មាត្រា ១៣

នៅថ្ងៃដែលមានការឱ្យសច្ចាប័នឬការចូលរួមចំនួនម្ភៃប្រទេស (ឬភាគី) អគ្គលេខាធិការត្រូវធ្វើជាកំណត់ហេតុហើយបញ្ជូនសំណៅចម្លងនៃកំណត់ហេតុនេះទៅគ្រប់សមាជិកនៃអង្គការសហប្រជាជាតិ និងគ្រប់រដ្ឋដែលមិនមែនជាសមាជិកទាំងឡាយដូចដែលបានចែងនៅក្នុងមាត្រា ៦។

អនុសញ្ញានេះនឹងសំរេចជាធរមាន (ប្រើប្រាស់បានតាមច្បាប់ពេល៩០ថ្ងៃក្រោយពីថ្ងៃដែលមានឯកសារឱ្យសច្ចាប័នឬឯកសារចូល រួមគ្រប់ចំនួនម្ភៃ។ ការឱ្យសច្ចាប័ន ឬការចូលរួមពីសំណាក់រដ្ឋឬភាគីថ្មីៗទៀតនឹងអាចសំរេចជាធរមាន( ទុកជាបានការ) នៅថ្ងៃទី ៩០ បន្ទាប់ពីការដំកល់ទុកនូវឯកសារនៃការសច្ចាប័ន ប្រការចូលរួមនេះពោលគឺភាគីដែលដាក់ពាក្យថ្មីៗត្រូវរងចាំបីខែទើបបានសំរេចជាធរមាន ។

## មាត្រា ១៤

អនុសញ្ញានេះមានអណត្តិចំនួន១០ឆ្នាំដោយចាប់រាប់ពីថ្ងៃដែលត្រូវចូលជាធរមានមក។ អនុសញ្ញានេះនឹងនៅ តែមានតម្លៃក្នុងរយៈពេលប្រាំឆ្នាំម្តងតទៅទៀត សំរាប់ភាគីដែលមិនបានសុំឈប់ទទួលស្គាល់អនុសញ្ញានេះក្នុងកំឡុងពេលយ៉ាងតិចចំនួនប្រាំមួយខែមុនថ្ងៃផុតកំណត់ នៃអណត្តិនៃអនុសញ្ញានេះ។ ការសុំឈប់ទទួលស្គាល់អនុសញ្ញានេះនឹងយកជាបានការ បើមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

## មាត្រា ១៥

ចំពោះការសុំលាឈប់ទទួលស្គាល់អនុសញ្ញានេះ បើសិនជាមានចំនួនភាគីជាសមាជិក( នៃអនុសញ្ញា) ថយចុះនៅតិចជាងដប់ប្រាំមួយនោះអនុសញ្ញានេះនឹងលែងមានតម្លៃតទៅទៀត ដោយចាប់ពីថ្ងៃដែលការសុំលាឈប់ចុងក្រោយបំផុតចូលជាធរមាន។

## មាត្រា ១៦

សំណើសុំសើរើពិនិត្យអនុសញ្ញានេះឡើងវិញអាចធ្វើឡើងបាននៅគ្រប់ពេលវេលាដោយភាគីណាមួយក៏បាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការ។ ប្រសិនបើមានករណីដូចខាងលើ មហាសន្និបាតនឹងកំណត់វិធានការណ៍ដែលត្រូវប្រកាន់យកនូវសំណើនេះ ។

## មាត្រា ១៧

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គ្រប់រដ្ឋជាសមាជិកអង្គការសហប្រជា ជាតិនិងរដ្ឋដែលមិនមែនជាសមាជិកនូវចំណុចមួយចំនួនដូចខាងក្រោមនេះ :

ក- ការចុះហត្ថលេខា ការឱ្យសច្ចាប័ននិងចូលរួម ដែលបានទទួលស្របតាមការអនុវត្តន៍មាត្រា ១១

ខ- ការជូនដំណឹងជាលាយលក្ខណ៍អក្សរស្របតាមការអនុវត្តន៍មាត្រា១២

គ- ថ្ងៃដែលអនុសញ្ញានេះបានសំរេចជាធរមានស្របតាមការអនុវត្តន៍មាត្រា ១៣

ឃ- ការសុំលាលែងដែលបានទទួលស្របតាមកាអនុវត្តន៍មាត្រា ១៤

ង- ការលុបអនុសញ្ញាចោលស្របតាមការអនុវត្តន៍មាត្រា ១៥

ច-ការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលអគ្គលេខាធិការបានទទួលដូចដែលបានពោលនៅក្នុងមាត្រា ១៦

## មាត្រា១៨

សំណៅដើមនៃអនុសញ្ញានឹងត្រូវដំកល់ទុកក្នុងប័ណ្ណសារដ្ឋាន( កន្លែងដំកល់ឯកសារ ) នៃអង្គការសហប្រជាជាតិ ។ សំណៅចំលងត្រឹមត្រូវតាមច្បាប់ដើមមួយច្បាប់ៗនឹងត្រូវបញ្ជូនទៅឱ្យគ្រប់រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ និងរដ្ឋដែលមិនមែនជាសមាជិកទាំងឡាយដែលបានចែងក្នុងមាត្រា ១១ ។

## មាត្រា ១៩

អនុសញ្ញានេះនឹងត្រូវចុះក្នុងបញ្ជីដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនៅថ្ងៃដែលចូលជាសមាជិក ។